
Julius Caesar
Augustus
ហេតុដូចម្តេចបានជា
ខែកុម្ភៈ
February
មាន 28 ថ្ងៃ
INVICTUS
ROMA

# តើហេតុដូចម្តេចបានជាខែកុម្ភៈមានតែ ២៨ ឬ ២៩ ថ្ងៃ ?

នេះជារឿងមិនចង់ចាញ់របស់ប្រមុខដឹកនាំក្រុងរ៉ូម Roma (ប្រទេសអ៊ីតាលីបច្ចុប្បន្ន)ដែលមានឈ្មោះថា Augustus កាលពី២០០០ឆ្នាំមុន ។ រឿងនេះទាក់ទង នឹងការបង្កើត ប្រក្រតិទិន សុរិយាគតិ ជាលើកដំបូង ដោយ Julius Caesar ដែលជាប្រមុខដឹកនាំក្រុង Roma មុន Augustus ។ ............

យើងត្រូវដឹងថាសម័យកាលណោះRomaជាមហាអំណាច លើពិភពលោកមានដែនអាណាចក្រគ្របដណ្តប់ស្ទើរពេញទូរទាំង ទ្វីបអឺរ៉ុប និង ភូមិភាគអាហ្វ្រិកខាងជើងមានប្រទេសអេហ្សុីបជាដើម។

.............

ដោយយល់ឃើញថាប្រក្រតិទិនច័ន្ទគតិមិនមានភាពទៀងទាត់ ធ្វើឲ្យមានផលអាក្រក់ដល់កសិកម្ម Juius Caesar បានបង្គាប់បញ្ជា ឲ្យប្រើ ដំណើរព្រះអាទិត្យពោលគឺ Equinox និង Solstice ជាគោលក្នុងការបង្កើត ប្រក្រតិទិន សុរិយាគតិ ......

ដំបូងឡើយគេបានសាកល្បងរូបមន្តៈ (31x6) + (30x6) = 366ថ្ងៃ ហើយខែកុម្ភៈជាខែទី១២ក្រោយគេ ឃើញថាមិនទាន់ត្រូវល្អ គឺរាងលើសធម្មតា គេក៏ដក ១ថ្ងៃពីខែកុម្ភៈដែលជាខែចុងក្រោយសល់ត្រឹម ២៩ថ្ងៃ ។ ក្រោយមកខែកុម្ភៈ ត្រូវ

បានយកមកដាក់ជាខែទីពីរវិញ ។ ១ ឆ្នាំ ពិតប្រាកដ មាន ៣៦៥ ថ្ងៃនិង៦ម៉ោង ដូច្នេះ៤ឆ្នាំម្តងគោងដំឡើង១ថ្ងៃ គឺថែមមួយថ្ងៃ លើខែកុម្ភៈ គឺ ៣០ថ្ងៃ ។ ............

Julius Caesar បានយកឈ្មោះគាត់ Julius ដាក់ជាឈ្មោះ ខែទី ៧ : Julius នេះជាឈ្មោះភាសា Latin, ជាអង់គ្លេស July និងជាបារាំង juillet.ដោយសារ Augustus ជាក្មួយរបស់គាត់ផង ជាកូនចិញ្ចឹមរបស់គាត់ផង ថែមទាំងជាអគ្គសេនាដៃស្តាំគាត់ទៀតគាត់បានយកឈ្មោះ Agustust ដាក់ជាខែទី ៨ បានជាអង់គ្លេស August និងបារាំង août ។ Julius Caesar ត្រូវបានគេធ្វើឃាតនៅ ឆ្នាំ ៤៤ មុនគ្រិស្តសករាជបន្ទាប់ពីបាន កំចាត់ពួកឃាតកររបស់ឪពុកចិញ្ចឹម របស់ខ្លួនអស់ហើយ Augustus បានឡើងជាប្រមុខក្រុង Roma ពេលនោះគាត់បាន បញ្ជកំណត់ឲ្យខែរបស់គាត់មាន៣១ថ្ងៃដូចខែរបស់ Julius ដែរ ។គេក៏ដក ១ថ្ងៃ អំពីខែកុម្ភៈមកថែមឲ្យខែសីហាតាមការកំណត់របស់ Augustus ។ដូច្នេះហើយទើបខែកុម្ភៈមានត្រឹម២៨ថ្ងៃហើយបួនឆ្នាំមាន២៩ថ្ងៃម្តង។

#############

មួយឆ្នាំប្រាកដមែនទែនមាន៣៦៥ថ្ងៃ ៥ម៉ោង ៤៨នាទី និង ៤៥វិនាទី